**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:០៤...សរ......**

## សារាចរ
## ស្តីពី
## ការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ ស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ រូបភាពអាសអាភាសកុមារ និងស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០២។ អនុលោមតាមមាត្រា១២និងមាត្រា៨ នៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារទាំង២ ក្នុងនាមជារដ្ឋភាគី បន្ទាប់ពីផ្តល់សច្ចាប័នរយៈពេល២ឆ្នាំ កម្ពុជាមានកាតព្វកិច្ចធ្វើរបាយការណ៍លើកដំបូង និងធ្វើរបាយការណ៍ទៀងទាត់រៀងរាល់៥ឆ្នាំម្តង ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ ជូនគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ។

នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១១ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់របាយការណ៍លើកទី១និងទី២ ជូនគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ដែលរៀបរាប់អំពីលទ្ធផលនៃការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជាពីឆ្នាំ២០០២ដល់ឆ្នាំ២០១០។ នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលបានទទួលកម្រងសំណួរពីគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ដើម្បីផ្តល់ព័ត៌មានបំពេញបន្ថែមលើរបាយការណ៍ជាតិលើកទី១និងទី២នេះ។ នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៤ រាជរដ្ឋាភិបាលបានផ្ញើរបាយការណ៍ឆ្លើយតបនឹងកម្រងសំណួរទៅគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ។

នៅថ្ងៃទី១២និងទី១៣ ខែមករា ឆ្នាំ២០១៥ គណៈប្រតិភូកម្ពុជាបានទៅចូលរួមបំភ្លឺលើការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅក្នុងសម័យប្រជុំលើកទី៦៨ របស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។ បន្ទាប់មកកម្ពុជាទទួលបាននូវអនុសាសន៍មួយចំនួនដែលជាការសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ដើម្បីឱ្យកម្ពុជាបន្តអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារឱ្យកាន់តែមានប្រសិទ្ធភាព។

ដើម្បីអនុវត្តអនុសាសន៍មួយចំនួនដែលមានលក្ខណៈវិជ្ជមាននិងស្ថាបនារបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិចំពោះព្រះរាជាណាចក្រកម្ពុជា និងដើម្បីជំរុញការអនុវត្តគោលនយោបាយជាតិចំពោះកុមារឱ្យទទួលបានជោគជ័យ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ៖

១- ក្រសួង ស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់អនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ដោយដាក់បញ្ចូលអនុសាសន៍ដែលពាក់ព័ន្ធទាំងនោះ ទៅនឹងភារកិច្ចរបស់ក្រសួង ស្ថាប័នសាមី និងអាជ្ញាធរថ្នាក់ក្រោមជាតិ និងត្រូវចាត់តាំងអនុវត្ត ដោយការទទួលខុសត្រូវខ្ពស់ដោយមានផែនការ គោលដៅ សកម្មភាព និងពេលវេលាកំណត់។

២. ក្រសួង ស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ត្រូវសហការជាមួយដៃគូអភិវឌ្ឍ អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តអនុសាសន៍ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់ខ្លួននិងអង្គការនានាឱ្យទទួលបានជោគជ័យ និងលើកកម្ពស់ការអនុវត្តសិទ្ធិកុមារនៅកម្ពុជាឱ្យបានកាន់តែល្អប្រសើរឡើង ក្នុងគោលដៅធានានូវឧត្តមប្រយោជន៍របស់កុមារ។

៣. រាជរដ្ឋាភិបាលកម្ពុជាសូមអំពាវនាវដល់ដៃគូអភិវឌ្ឍ អង្គការជាតិ អង្គការអន្តរជាតិ និងវិស័យឯកជនដែលពាក់ព័ន្ធទាំងអស់ ឲ្យចូលរួមសហការនិងផ្តល់ការឧបត្ថម្ភគាំទ្រដល់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារគ្រប់ថ្នាក់ និងក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ក្នុងការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ សំដៅជំរុញការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ឱ្យទទួលជោគជ័យថែមទៀត។

៤. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួង ស្ថាប័នពាក់ព័ន្ធ លើកគម្រោងចំណាយនានា ដើម្បីអនុវត្តសកម្មភាពអាទិភាព ដែលមានចែងនៅក្នុងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ និងដាក់បញ្ចូលទៅក្នុងផែនការថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ននីមួយៗ ដោយអនុលោមទៅតាមច្បាប់ហិរញ្ញវត្ថុជាធរមាន។

៥. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវយកចិត្តទុកដាក់ធ្វើការផ្សព្វផ្សាយសារាចរណែនាំនេះ ជាមួយនឹងសេចក្តីសង្កេតចុងក្រោយ រួមទាំងអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ព្រមទាំងត្រូវតាមដាននិងធ្វើរបាយការណ៍ស្តីពីការអនុវត្តសារាចរណែនាំនេះ ជាប្រចាំជូនរាជរដ្ឋាភិបាល។

៦. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវសម្របសម្រួលសហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការជាតិ អង្គការអន្តរជាតិនិងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ តាមកាលកំណត់បន្ទាប់ទៀត។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ